**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍**
**និងគ្រឿងញៀន**
លេខ: ០៤៧ កប/គបអគញ

**សូមគោរពជូន**
**ឯកឧត្តមទេសរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

**កម្មវត្ថុ:** របាយការណ៍បូកសរុបលទ្ធផលការងារស្តីពីការបង្ការនិងការប្រយុទ្ធទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ និងគ្រឿងញៀនប្រចាំនព្វមាស និងទិសដៅអនុវត្តត្រីមាសទី៤ ឆ្នាំ២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍សូមជម្រាបជូន **ឯកឧត្តមប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍** មេត្តាជ្រាបដូចខាងក្រោម:

**ក- លទ្ធផលការងារដែលសម្រេចបាន**

**I-ការប្រជុំ និងការងារផ្សេងៗរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ក្រសួង**

-កិច្ចប្រជុំប្រចាំត្រីមាសរបស់គណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀនក្រោមអធិបតីភាព ឯកឧត្តមវេជ្ជ. **ហ៊ុយ ហានសុង** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀន សរុបសមាជិកចូលរួម ៣០ នាក់ (ស្រី ១៣នាក់) ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ នៅអគារទីស្តីការក្រសួង។

-កិច្ចប្រជុំចំនួន ៣ លើករៀបចំសេចក្តីព្រាង សេចក្តីណែនាំ ស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១ នៅកម្ពុជា នៅលេខាធិការដ្ឋានអេដស៍ និងគ្រឿងញៀន ទីស្តីការក្រសួង។

-បានបោះពុម្ពសៀវភៅគោលការណ៍ណែនាំប្រកាសលេខ១៩៤ ក.ប/ប្រ.ក ស្តីពីលក្ខខណ្ឌការងារវិធានអនាម័យ និងសន្តិសុខការងារនៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុនផ្នែកសេវាកម្សាន្ត ចំនួន៥.០០០ក្បាល។

-កិច្ចប្រជុំឆ្លងសេចក្តីណែនាំស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅតាមសហគ្រាស គ្រឹះស្ថាន ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៧ នៅទីស្តីការក្រសួង។